នស/រកត/០៦០៦/២៤៨

# ព្រះរាជក្រឹត្យ
## ស្តីពី
## ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ហៅកាត់ អ.ព.វ ដែលជាគ្រឹះស្ថានសាធារណៈមួយប្រកបដោយបុគ្គលភាពគតិយុត្ត មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ។

គ្រឹះស្ថានសាធារណៈនេះ ស្ថិតនៅក្រោមអាណាព្យាបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

**មាត្រា ២.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារមានបេសកកម្មគិតគូរ ដឹកនាំ ការងាររៀបចំ និងអភិវឌ្ឍទេសចរណ៍ នៃតំបន់ចំនួន៤ (បួន) ដែលកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/ ១៨៣ ចុះថ្ងៃ ទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ។

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារព្រមជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើជាអាណាព្យាបាលរួមលើគ្រឹះស្ថាន និងនាយកដ្ឋានទាំងឡាយ ដែលមានភារកិច្ចទទួលខុសត្រូវជាក់ស្តែង ក្នុងការគ្រប់គ្រងរមណីយដ្ឋានប្រាសាទព្រះវិហារ ។

**មាត្រា ៣.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវកំណត់ឱ្យមាន សៀវភៅបន្ទុកសម្រាប់អង្គការនានា ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងរមណីយដ្ឋាន និងការរៀបចំតំបន់ប្រាសាទព្រះវិហារ ។ ក្នុងន័យនេះ អាជ្ញាធរជាតិអាច :

- ចុះកិច្ចសន្យា អំពីកម្មវិធីប្រចាំឆ្នាំជាមួយអង្គការជាតិ និងអន្តរជាតិនានា
- ចុះកិច្ចសន្យា ជាមួយអាជ្ញាធរខេត្តដែលមានបំណងធ្វើការរៀបចំនគរូបនីយកម្ម ការអភិវឌ្ឍជនបទ និង ការផ្តល់សេវាផ្សេងៗជាយថាហេតុ
- សហការជាមួយគ្រប់វិទ្យាស្ថាន គ្រប់អង្គការផ្សេងៗ គ្រប់មូលនិធិ និងសហគមន៍ជាតិ និងអន្តរជាតិ ដែលដើរ តាមទិសដៅ ឆ្លើយតបនឹងសមត្ថកិច្ចអាជ្ញាធរជាតិ ។

**មាត្រា ៤.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវធ្វើរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ អំពីសកម្មភាពការងារ ការវិនិយោគ និងសេចក្តីអនុញ្ញាតផ្សេងៗ ដែលត្រូវបាន សម្រេចហើយ ជូនប្រមុខរាជរដ្ឋាភិបាល ។

## ជំពូកទី ២

## ក្រុមប្រឹក្សាភិបាល

**មាត្រា ៥.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវបានដឹកនាំដោយ ក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាពដូចតទៅ :

- ឥស្សរជនមួយរូប ប្រធាន
- អភិបាលខេត្តព្រះវិហារ សមាជិក
- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិវឌ្ឍសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

- តំណាងក្រសួងទេសចរណ៍ សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងបរិស្ថាន សមាជិក
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ សមាជិក និងលេខាធិការ ។

សមាសភាពក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាភិបាល មានភារកិច្ចដឹកនាំអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ និងមានសិទ្ធិអនុម័ត :

- ការតម្រង់ទិសរាល់សកម្មភាពរបស់អាជ្ញាធរជាតិ
- ការអនុញ្ញាតឱ្យប្រធានអាជ្ញាធរជាតិ ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាអន្តរជាតិទាំងឡាយ ស្របតាមនីតិវិធីជាធរមាន
- បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរជាតិ
- របាយការណ៍ប្រចាំឆ្នាំ ដែលប្រធានអាជ្ញាធរជាតិបានដាក់ជូន
- ចំនួនទឹកប្រាក់ ថ្លៃឈ្នួលផ្សេងៗ និងចំណូលគ្រប់បែបដែលអាជ្ញាធរប្រមូលបាន
- ចំនួនទឹកប្រាក់ និងលក្ខខណ្ឌនៃការខ្ចីបុល
- រាល់វិធានការ ដំណោះស្រាយបញ្ហាដែលប្រធានអាជ្ញាធរជាតិ ដាក់ជូនពិនិត្យ ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាភិបាល ត្រូវប្រជុំសាមញ្ញយ៉ាងតិច ២ (ពីរ) ដង ក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល និងអាចប្រជុំវិសាមញ្ញតាមការចាំបាច់ ក្នុងករណីមានការស្នើសុំពីប្រធាន ឬសមាជិកចំនួន ១/៤ ។

ប្រធានក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជន ឬអ្នកជំនាញ និងតំណាងក្រសួង ស្ថាប័ន ជាលក្ខណៈពិគ្រោះយោបល់មកចូលរួមបានក្នុងអង្គប្រជុំ បានតាមការចាំបាច់ដើម្បីផលប្រយោជន៍សម្រាប់អាជ្ញាធរជាតិនេះ ។

**មាត្រា ៨.-**

អាណត្តិសមាជិកក្រុមប្រឹក្សាភិបាល មានរយៈពេល ៣ (បី) ឆ្នាំ ហើយអាចបន្តសាជាថ្មីបាន។ ការបញ្ចប់អាណត្តិសមាជិកណាម្នាក់ ត្រូវធ្វើឡើងតាមសំណើរបស់ក្រសួងសាមី ។

**មាត្រា ៩.-**

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីអាណាព្យាបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

## ជំពូកទី ៣
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ១០.-**

ប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ គឺជាប្រធានអាជ្ញាធរជាតិនេះ ដែលមានសិទ្ធិអំណាចដូចមានចែងនៅក្នុងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងមានតួនាទី និងភារកិច្ចបន្ថែម ដូចតទៅ :

- ជាតំណាងឱ្យរាជរដ្ឋាភិបាលក្នុងគ្រប់កិច្ចប្រជុំ ពិធី និងការចរចាដែលពាក់ព័ន្ធនឹងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាទាំងឡាយដែលទាក់ទងនឹងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- ទទួលរ៉ាប់រងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងចាត់វិធានការគ្រប់គ្រងក្នុងដំណើរការរបស់អាជ្ញាធរជាតិ
- ជាអាណាប័កដើមខ្សែនៃអាជ្ញាធរជាតិ ដែលមានតួនាទីត្រួតពិនិត្យចំណូល និងបញ្ជាចំណាយផ្សេងៗ
- តែងតាំង និងដំឡើងឋានន្តរស័ក្តិភ្នាក់ងារ និងបុគ្គលិក បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល
- ដឹកនាំ គ្រប់គ្រងជាប្រចាំលើសកម្មភាពការងាររបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិនេះ ។

**មាត្រា ១១.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ មានអគ្គនាយកដ្ឋានមួយជាសេនាធិការ ដែលត្រូវបានដឹកនាំ គ្រប់គ្រង ដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនតាមការចាំបាច់ ។ អគ្គនាយក និងអគ្គនាយករងនៃអគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិនេះ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១២.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ទទួលបន្ទុកការពារ អភិរក្ស និងគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ត្រូវធ្វើសកម្មភាពឱ្យស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា៥ នៃព្រះរាជក្រមលេខ នស/រកម/ ០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ និងព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ព្រមទាំងកាតព្វកិច្ចអន្តរជាតិ ។

អាជ្ញាធរជាតិនេះ មានសិទ្ធិផ្តាច់មុខ ក្នុងការចេញលិខិតអនុញ្ញាតសាងសង់ សម្រាប់ការស្ថាបនាទាំងឡាយក្នុងរង្វង់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ។ ការអនុញ្ញាតសាងសង់ដែលចេញដោយអាជ្ញាធរផ្សេងក្រៅពីអាជ្ញាធរជាតិនេះ ទាក់ទងទៅនឹងសំណង់នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារត្រូវចាត់ទុកជាមោឃៈ ។ សំណង់កសាងរួចហើយក្នុងតំបន់ការពារដែលគ្មានច្បាប់អនុញ្ញាត ត្រូវរុះរើចេញដោយម្ចាស់សំណង់ដោយគ្មានលក្ខខណ្ឌ ក្នុងរយៈពេល ៤៥ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃជូនដំណឹង ។

អាជ្ញាធរជាតិនេះត្រូវទទួលភារកិច្ចផ្ដាច់មុខ ជាអ្នកចាត់ចែងគ្រប់ការងារទាំងអស់ក្នុងបរិវេណរមណីយដ្ឋាននេះ លើកលែងតែកិច្ចការណាដែលទាក់ទងនឹងបញ្ហាព្រំដែន ។

## ជំពូកទី ៤
## វិសមិតភាព

**មាត្រា ១៣.-**

ប្រធាន សមាជិកទាំងអស់ និងនាយកហិរញ្ញកិច្ច និងគណនេយ្យ នៃក្រុមប្រឹក្សាភិបាលរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ពុំអាចទទួលផលប្រយោជន៍អ្វី ដោយផ្ទាល់ ឬតាមរយៈស្វាមី ឬភរិយា ឬកូនរបស់ខ្លួននៅក្នុងសហគ្រាសឯកជនណាមួយ ដែលធ្វើអាជីវកម្មក្រោមសមត្ថកិច្ចអាជ្ញាធរជាតិនេះឡើយ ។

ក្នុងករណីមិនគោរពកាតព្វកិច្ចនេះ ក្រុមប្រឹក្សាភិបាលត្រូវធ្វើកំណត់ហេតុស្ដីពីវិសមិតភាពការងាររបស់សាមីជន ហើយប្រកាសឱ្យលាលែងពីមុខតំណែងតែម្ដង ។

## ជំពូកទី ៥
## ប្រភពធនធាន

**មាត្រា ១៤.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ មានធនធានជា :

- វិភាគទានពីរដ្ឋ និងពីឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង
- អំណោយ និងវិភាគទានអន្តរជាតិ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិនេះ
- ចំណូលបានមកពីសកម្មភាពផ្ទាល់របស់អាជ្ញាធរជាតិ ដូចជាបំណុល ថ្លៃឈ្នួល បានមកពីការចេញច្បាប់កាន់កាប់ផ្សេងៗ
- ប្រាក់កម្រៃបានមកពីប្រភពសេវាកម្មផ្សេងៗ ផ្ដល់មកពីអង្គការសាធារណៈ ឬឯកជន
- កម្ចីដែលធ្វើឡើងតាមការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ
- ចលនវត្ថុ និងអចលនវត្ថុ ដែលសប្បុរសជន អង្គការជាតិ និងអន្តរជាតិប្រគល់ឱ្យ ។

**មាត្រា ១៥.-**

គម្រោងចំណូល និងចំណាយសម្រាប់ឆ្នាំបន្ទាប់ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តយ៉ាងយូរបំផុតនៅថ្ងៃទី ០១ ខែតុលា ។

## ជំពូកទី ៦
## អវសានបញ្ញត្តិ

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិក្រមសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

**មាត្រា ១៧.-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៦០៦.២៥៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

ហត្ថលេខា

សុខ អាន

លេខ : ២៤០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ឌិនកេន**